ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០២ . អនក្រ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការកសាងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ០៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០២/០៤០ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៤/២៣៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការកែតម្រូវមាត្រា ១ មាត្រា ២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០២/០៤០ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- យោងតាមតម្រូវការចាំបាច់នៃការងារ

## ស ម្រេ ច

**ប្រការ ១ :** ត្រូវបានបង្កើតគណៈកម្មការកសាងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ដែលមានសមាសភាព ដូចតទៅ ÷

www.pheakdeylaw.com

| | | |
|---|---|---|
| ១-ឯកឧត្តម ញឹម វណ្ណដា | ទេសរដ្ឋមន្ត្រី អនុប្រធានទី ១ គ.ជ.គ.ម | ប្រធាន |
| ២-ឯកឧត្តម លី ធុជ | ទេសរដ្ឋមន្ត្រី អនុប្រធានទី ២ គ.ជ.គ.ម | អនុប្រធាន |
| ៣-ឯកឧត្តម ម៉ុង សំផន | រដ្ឋលេខាធិការ ក្រសួងការពារជាតិ | អនុប្រធាន |
| ៤-ឯកឧត្តម ពៅ សាមី | អគ្គលេខាធិការ គ.ជ.គ.ម | អនុប្រធាន |
| ៥-ឯកឧត្តម សំ សារិត | រដ្ឋលេខាធិការ ក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៦-ឯកឧត្តម ខាយ ឃុនហេង | រដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៧-ឯកឧត្តម ម៉ុន ឈារិទ្ធិ | អគ្គលេខាធិការរង គ.ជ.គ.ម | សមាជិក |
| ៨-ឯកឧត្តម គឹម វណ្ណរ៉ា | អគ្គលេខាធិការរង គ.ជ.គ.ម | សមាជិក |
| ៩-ឯកឧត្តម នូ ឃុត | អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១០-ឯកឧត្តម ហ៊ូ តាំងអេង | អនុរដ្ឋលេខាធិការ ក្រសួងផែនការ | សមាជិក |
| ១១-ឯកឧត្តម ប្រុក សារឿន | ប្រធានក្រុមប្រឹក្សានីតិកម្ម ក្រសួងមហាផ្ទៃ | សមាជិក |
| ១២-ឯកឧត្តម ទេជ តៃ គុយស៊ាង | អនុរដ្ឋលេខាធិការ ក្រសួងសុខាភិបាល | សមាជិក |
| ១៣-ឯកឧត្តម ឈួន ដារ៉ា | អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៤-ឯកឧត្តម នា ជុច | អនុរដ្ឋលេខាធិការ ក្រសួងបរិស្ថាន | សមាជិក |
| ១៥-ឯកឧត្តម គឹម សុគំណរ | អនុរដ្ឋលេខាធិការ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ១៦-ឯកឧត្តម ជួប សុគន្ធី | អនុរដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៧-ឯកឧត្តម ឡៀង វណ្ណដារ៉ុង | អនុរដ្ឋលេខាធិការ ក្រសួងព័ត៌មាន | សមាជិក |
| ១៨-ឯកឧត្តម អៀម សារ៉ី | អនុរដ្ឋលេខាធិការ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | សមាជិក |
| ១៩-ឯកឧត្តម ទ្រី ម៉េង | អនុរដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ២០-ឯកឧត្តម យាង សេង | សមាជិកបំរុង ក្រុមប្រឹក្សាអ្នកច្បាប់ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ២១-ឯកឧត្តម ជៃ សុខខេង | អគ្គលេខាធិការរង ក្រុមប្រឹក្សាអ្នកច្បាប់ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ២២-ឯកឧត្តម និត ហ៊ើល | នាយកខុទ្ទកាល័យ គ.ជ.គ.ម | សមាជិក |
| ២៣-ឯកឧត្តម សៅ សុវណ្ណ | ទីប្រឹក្សា គ.ជ.គ.ម | សមាជិក |
| ២៤-ឯកឧត្តម ឡាំ ហេងហួត | ទីប្រឹក្សា គ.ជ.គ.ម | សមាជិក |
| ២៥-លោកស្រី ជួង រដ្ឋនី | អគ្គនាយករង ក្រសួងកិច្ចការនារី | សមាជិក |
| ២៦-លោក ហង្ស ប៊ុណ្ណាក់ | អគ្គនាយករង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ២៧-លោក ផាត់ ពៅស៊ាង | មេធាវី | សមាជិក |
| ២៨-លោក បណ្ឌិត សុខ សាឈន់ | មេធាវី | សមាជិក |

www.pheakdeylaw.com

| | | |
|---|---|---|
| ២៩-លោក កៅ ថ៊ុនហុង | មេធាវី | សមាជិក |
| ៣០-លោក អេង គឹមលី | តំណាង ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៣១-លោក ឌុច សំអាង | តំណាង កាកបាទក្រហមកម្ពុជា | សមាជិក ។ |

គណៈកម្មការកសាងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ មានភារកិច្ចដូចតទៅ ÷

-ធ្វើការពិគ្រោះយោបល់ជាមួយអាជ្ញាធរដែនដី និងដៃគូអភិវឌ្ឍន៍នានា លើព័ត៌មាន និងទិន្នន័យដែលពាក់ព័ន្ធ ដើម្បីឱ្យការកសាងសេចក្តីព្រាងច្បាប់មានមូលដ្ឋានគ្រប់គ្រាន់

-អញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ពន្ធ័ អាជ្ញាធរដែនដី ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការជាតិ និងអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ចូលរួមប្រជុំ សិក្ខាសាលាពិភាក្សាផ្តល់ទិន្នន័យចូលបន្ថែមលើសេចក្តីព្រាងច្បាប់

-ពិនិត្យ ពិចារណា និងសម្រេចយល់ព្រមលើសេចក្តីព្រាងច្បាប់ ដើម្បីដាក់ជូនកិច្ចប្រជុំអន្តរក្រសួងពិនិត្យ ផ្តល់យោបល់ មុនដាក់ឆ្លងកិច្ចប្រជុំពេញអង្គនៃគណៈរដ្ឋមន្ត្រី

-បូកសរុបធ្វើរបាយការណ៍ជូនគណៈរដ្ឋមន្ត្រី ។

**ប្រការ ២ :** ត្រូវបានបង្កើតក្រុមលេខាពិគ្រោះយោបល់ ជាជំនួយការដល់គណៈកម្មការកសាងសេចក្តីព្រាងច្បាប់ ដែលមានសមាសភាព ដូចតទៅ ÷

| | | |
|---|---|---|
| ១-ឯកឧត្តម ពៅ សាមី | អគ្គលេខាធិការ គ.ជ.គ.ម | ប្រធាន |
| ២-ឯកឧត្តម ហ៊ី សាំងអេង | អនុរដ្ឋលេខាធិការក្រសួងផែនការ | អនុប្រធាន |
| ៣-ឯកឧត្តម ផៃ ស៊ុខខេង | អគ្គលេខាធិការរង ក្រុមប្រឹក្សាអ្នកច្បាប់ ទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៤-ឯកឧត្តម ម៉ុន សារិទ្ធិ | អគ្គលេខាធិការរង គ.ជ.គ.ម | អនុប្រធាន |
| ៥-ឯកឧត្តម គឹម ចន្ទ្រា | អគ្គលេខាធិការ គ.ជ.គ.ម | សមាជិក |
| ៦-ឯកឧត្តម រស់ សុវណ្ណ | ទីប្រឹក្សា គ.ជ.គ.ម | សមាជិក |
| ៧-ឯកឧត្តម យាង សេង | សមាជិកបំរុង ក្រុមប្រឹក្សាអ្នកច្បាប់ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៨-ឯកឧត្តម ឡាំ ហេងហួត | ទីប្រឹក្សា គ.ជ.គ.ម | សមាជិក |
| ៩-លោក ង៉ាត់ ពៅស៊ាង | មេធាវី | សមាជិក |
| ១០-លោក បណ្ឌិត សុខ សាឈន់ | មេធាវី | សមាជិក |
| ១១-លោក កៅ ថ៊ុនហុង | មេធាវី | សមាជិក |
| ១២-លោក ឧត្តមសេនីយ៍ ជា លីស្រ៊ុន | ជំនួយការ គ.ជ.គ.ម | សមាជិក |
| ១៣-លោក ឃុន សុខា | ប្រធាននាយកដ្ឋានបណ្តុះបណ្តាល | លេខាធិការ |
| ១៤-លោក កែវ ទី | ជំនួយការ អនុប្រធានទី ១ | លេខាធិការ ។ |

ក្រុមលេខាពិគ្រោះយោបល់ មានភារកិច្ចដូចតទៅ ÷

-ប្រមូលព័ត៌មាន ឯកសាររបស់ក្រសួង ស្ថាប័នពាក់ពន្ធ័ សំរាប់ធ្វើជាមូលដ្ឋានក្នុងការកសាងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ

-សិក្សាស្រាវជ្រាវ វិភាគ សំយោគ និងវាយតម្លៃនូវសកម្មភាពនានាដែលទាក់ទងនិងការងារគ្រប់គ្រងគ្រោះមហន្តរាយ សំរាប់បញ្ចូលក្នុងខ្លឹមសារសេចក្តីព្រាងច្បាប់

-រៀបចំតាក់តែងសេចក្តីព្រាងច្បាប់ និងដាក់ឆ្លងគណៈកម្មការពិនិត្យ និងសម្រេច ។

**ប្រការ ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចចែងក្នុងប្រការ ១ និងប្រការ ២ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

***កន្លែងទទួល :***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

www.pheakdeylaw.com